ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៤ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១(ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- តាមសំណើរបស់រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម** | ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត **សន ពៅ** | អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | អនុប្រធាន |
| ៣. ឯកឧត្តមបណ្ឌិត **ជួរ គារី** | ប្រធានវិទ្យាស្ថានភាសាជាតិ | អនុប្រធាន |
| ៤. ឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់** | ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ | ទីប្រឹក្សា |
| ៥. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ | ទីប្រឹក្សា |
| ៦. ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** | ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ | ទីប្រឹក្សា |
| ៧. ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** | ទីប្រឹក្សារាជរដ្ឋាភិបាល និងជាឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ | ទីប្រឹក្សា |
| ៨. ឯកឧត្តម **សូ មុយឃៀង** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | ទីប្រឹក្សា |
| ៩. ឯកឧត្តមបណ្ឌិតសភាចារ្យ **សោម សុមុនី** | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជាទទួលបន្ទុកជាប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ១០. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ១១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ១២. ឯកឧត្តមបណ្ឌិត **យង់ ពៅ** | អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៣. ព្រះសុមេធវង្សបណ្ឌិត **សុខ ប៊ុនធឿន** | ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយឧត្តមសិក្សានៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និងសាសនា និងជាព្រះចៅអធិការវត្តនន្ទមុនី | សមាជិក |
| ១៤. ព្រះគ្រូចរណាវិជ្ជា **ផល សុភឿន** | ព្រះសមុហ៍អនុគណខណ្ឌពោធិសែនជ័យ និងជាព្រះចៅអធិការវត្តព្រៃស្ពឺ | សមាជិក |
| ១៥. ឯកឧត្តមបណ្ឌិត **ម៉ៅ សុភ្កន** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |

| | | |
|---|---|---|
| ១៦. លោក **ស សុខនី** | ប្រធាននាយកដ្ឋានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ និងសាសនា និងជា សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ១៧. លោកបណ្ឌិត **ខង្យ មេង** | អនុប្រធានវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១៨. លោកបណ្ឌិត **ប៊ី សុខគង់** | ប្រធានផ្នែកភាសា និងភាសាវិទ្យា នៃវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១៩. លោកបណ្ឌិត **ណុន សុខា** | ប្រធានផ្នែកអក្សរសាស្ត្រ និងអក្សរសិល្ប៍ នៃវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ២០. លោកស្រីបណ្ឌិត **ភាវ ណាង** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | សមាជិកា |
| ២១. លោកស្រីបណ្ឌិត **ហាង់ ថាវី** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | សមាជិកា |
| ២២. លោកបណ្ឌិត **ជុំ ស៊ុនណាង** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ២៣. លោក **គុយ រិន** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ២៤. លោកបណ្ឌិត **ឈិត វណ្ណាឫទ្ធិ** | អ្នកជំនាញប្រព័ន្ធទិន្នន័យ | សមាជិក |
| ២៥. លោក **អុក ចួន** | សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ២៦. លោក **សឹង ផុស** | សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ២៧. លោក **យឿង ទីរបុត្រ** | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ២៨. លោកស្រី **កែប សុគន្ធារតន៍** | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ២៩. លោក **ចែម វត្ថុ** | មន្ត្រីអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣០. លោក **លឹម លឿម** | គ្រូបង្រៀនភាសាបាលីពុទ្ធិកបឋមសិក្សាវត្តព្រៃស្តី ខណ្ឌពោធិ៍សែនជ័យ | សមាជិក។ |

**ប្រការ២.-**

សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំការប្រជុំដោយមានការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៣.-**

គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ មានភារកិច្ចរៀបចំធ្វើវចនានុក្រមភាសាខ្មែរ ដោយឈរលើស្មារតីអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ និងយកវចនានុក្រមខ្មែររៀបចំដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត** ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ ជាគោល។

**ប្រការ៤.-**

គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗ ជាជំនួយការតាមការចាំបាច់។

**ប្រការ៥.-**

គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ អាចមានសិទ្ធិប្រើប្រាស់ថវិកាជាតិ រួមទាំងកញ្ចប់ថវិកាដោយឡែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល និងមានសិទ្ធិទទួលអំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍន៍ សហគមន៍ជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងពីសប្បុរសជននានា។

**ប្រការ៦.-**

សេចក្តីសម្រេចលេខ២៦ សសរ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០ កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ